ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ១៧៤ អនក្រ.បក

ក្រសួងទំនាក់ទំនងរដ្ឋសភា ... លេខ ១៣៩៧ ន.រប ថ្ងៃទី ... ខែ ... ឆ្នាំ២០០៦ ម៉ោង ...

ចំលងច្បាប់

នាយកដ្ឋាន.រដ្ឋបាល.

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៥ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៦។

# **សម្រេច**

**មាត្រា ១ .-**

បង្កើត **គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **គ.ជ.គ.ប.អ** ជាភាសាអង់គ្លេសហៅថា National Climate Change Committee (NCCC) ក្នុងទិសដៅរៀបចំ សម្របសម្រួល និងតាមដានពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាល សំដៅឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុក្នុងប្រទេស រួមចំណែកការពារបរិស្ថាន និងធនធានធម្មជាតិ ដើម្បីឱ្យបានដឹងជាមុន និងទប់ស្កាត់ការប្រែប្រួលអាកាសធាតុបណ្តាលមកពីមនុស្ស ដែលអាចបង្កឥទ្ធិពលអវិជ្ជមានចំពោះសុខុមាលភាពនៃមនុស្សជាតិ ។

**មាត្រា ២ ថ្មី .-**

**គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ** ជាយន្តការអន្តរក្រសួង មានចរិតលក្ខណៈ អន្តរវិស័យ និងពហុជំនាញ ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | | ប្រធានកិត្តិយស |
| ២. | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ៣. | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | មួយ (០១) រូប | អនុប្រធាន |
| ៤. | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | មួយ (០១) រូប | អនុប្រធាន |
| ៥. | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | មួយ (០១) រូប | អនុប្រធាន |
| ៦. | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ✓ | មួយ (០១) រូប | សមាជិក |
| ៧. | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | មួយ (០១) រូប | សមាជិក |
| ៨. | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយ (០១) រូប | សមាជិក |
| ៩. | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មួយ (០១) រូប | សមាជិក |
| ១០. | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | មួយ (០១) រូប | សមាជិក |
| ១១. | អនុរដ្ឋលេខាធិការក្រសួងផែនការ | មួយ (០១) រូប | សមាជិក |
| ១២. | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | មួយ (០១) រូប | សមាជិក |
| ១៣. | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | មួយ (០១) រូប | សមាជិក |
| ១៤. | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | មួយ (០១) រូប | សមាជិក |
| ១៥. | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | មួយ (០១) រូប | សមាជិក |
| ១៦. | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | មួយ (០១) រូប | សមាជិក |

១៧. អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន មួយ (០១) រូប សមាជិក

១៨. អគ្គលេខាធិការរងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មួយ (០១) រូប សមាជិក

១៩. អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយ (០១) រូប សមាជិក

២០. អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មួយ (០១) រូប សមាជិក

**មាត្រា ៣ .-**

**គ.ជ.គ.ប.អ** មានតួនាទី និងភារកិច្ច សម្របសម្រួល និងសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងទិសដៅដូចតទៅ :

- រៀបចំសេចក្តីព្រាងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដោយរួមទាំងផែនការជាតិកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងផែនការជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- ជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយ ពីភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងការរៀបចំ និងក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ ឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងបណ្តាអាទិភាព និងគោលដៅអភិវឌ្ឍន៍របស់ជាតិ
- ជំរុញ និងលើកទឹកចិត្តការដាក់បញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ដែលពាក់ព័ន្ធ
- កៀរគរធនធានដែលចាំបាច់ ពិសេសការទាក់ទាញជំនួយឥតសំណង សម្រាប់អនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ បរិធានច្បាប់ ផែនការ និងកម្មវិធីនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ជំរុញ និងលើកទឹកចិត្តការផ្ទេរបច្ចេកវិជ្ជាថាមពលសមស្រប និងថាមពលកកើតឡើងវិញ ការអភិរក្ស និងការកែលំអអាងផ្ទុកកាបូន
- កំណត់គោលជំហរ និងយុទ្ធសាស្ត្រជាតិ សម្រាប់ចូលរួមក្នុងកិច្ចចរចា នៃកិច្ចប្រជុំអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ
- ពិនិត្យ និងអនុម័តលើរបាយការណ៍ផ្លូវការនានារបស់ជាតិ ដែលតម្រូវឱ្យរៀបចំ នៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
- សម្របសម្រួលសកម្មភាពនានា ដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ពិធីសារនានាក្រោមអនុសញ្ញានេះ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ស្តីពីការប្រែប្រួលអាកាសធាតុ ដែលភាគីកម្ពុជាបានចូលជាសមាជិករួចហើយ
- ទទួលបន្ទុកគ្រប់គ្រង និងសម្របសម្រួលការងារយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ នៅកម្ពុជា

- ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុ ការអនុវត្តអនុសញ្ញាស្ដីពីការប្រែប្រួលអាកាសធាតុ និងដំណើរការចរចាថ្នាក់អន្តរជាតិ
- ជំរុញការអប់រំ ការយល់ដឹង ការបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ ស្ដីពីការប្រែប្រួលអាកាសធាតុ
- ចូលរួមក្នុងកិច្ចប្រជុំ សន្និសីទ និងសិក្ខាសាលាថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ស្ដីពីបញ្ហាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ
- សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តបណ្ដាគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានា ដែលពាក់ព័ន្ធនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ពិនិត្យ និងអនុម័តលើផែនការការងារ និងរបាយការណ៍នានារបស់ **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** ហៅកាត់ថា **ក.ប.ក.ប.អ** (Climate Change Technical Team: CCTT) ដែលនឹងត្រូវបង្កើតឡើង អនុលោមតាមមាត្រា ៤ នៃអនុក្រឹត្យនេះ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុ។

**មាត្រា ៤ .-**

**គ.ជ.គ.ប.អ** ត្រូវរៀបចំបង្កើត **ក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុ** (**ក.ប.ក.ប.អ**)។ **ក.ប.ក.ប.អ** មានភារកិច្ចទទួលខុសត្រូវលើការងារបច្ចេកទេស និងលើកមតិយោបល់ ដែលទាក់ទងទៅនឹងការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា ជូនដល់ **គ.ជ.គ.ប.អ** ក្នុងការបំពេញភារកិច្ច ដូចមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

**ក.ប.ក.ប.អ** មានមន្ត្រីជំនាញ ជាតំណាងមកពីបណ្ដាក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលមានបេសកកម្មពាក់ព័ន្ធនឹងការងារប្រែប្រួលអាកាសធាតុ និងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ ។ **ក.ប.ក.ប.អ** មានទីតាំងនៅក្រសួងបរិស្ថាន។

**មាត្រា ៥ .-**

សមាជិក **គ.ជ.គ.ប.អ** ទាំងអស់ ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់ តាមការកោះអញ្ជើញរបស់ប្រធាន **គ.ជ.គ.ប.អ** ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំការប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន។ អង្គការជាតិ អង្គការអន្តរជាតិដែលពាក់ព័ន្ធ អាចចូលរួមប្រជុំបាន តាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានទទួលសិទ្ធិ ។

**គ.ជ.គ.ប.អ** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន។

**មាត្រា ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីនៃក្រសួងនិងប្រធាននៃស្ថាប័នដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ